ក N°33/16→04/5/2016

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៣-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤១៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ឥស្សរជន ចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម ៣៧៧៣

២៣-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤១៩ ស្តីពី ការតែងតាំងឥស្សរជន ០២ រូប ជាអនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល ៣៧៧៤

២៣-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២០ ស្តីពី ការដាក់មន្ត្រីរាជការ ០៤ រូប របស់ក្រសួង ចំនួន ៤ ឱ្យចូលនិវត្តន៍ ៣៧៧៥

២៣-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ៣៧៧៧

២៣-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២២ ស្តីពី ការតម្លើងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់ឯកឧត្តម **លីវ គឹមហេង** ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៣៧៧៨

២៥-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២៣ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ហែម ចន្ថា** ជានាយកវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈ ស្មើ អគ្គនាយក ៣៧៧៩

២៥-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២៤ ស្តីពី ការតម្លើងឋានៈឯកឧត្តម **ពាន់ ឌីម** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈ ស្មើ អនុរដ្ឋលេខាធិការ ៣៧៨០

២៥-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២៥ ស្តីពី ការផ្ទេរបញ្ចូលក្របខ័ណ្ឌ ជាករណីពិសេស លោក **ហឿង សុគន្ធ** ក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ មកក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៣៧៨១

២៥-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ចំនួន ០៩ រូប ៣៧៨២

២៥-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ស៊ី លី** (SHI LI) ជនជាតិចិន សញ្ជាតិចិន ៣៧៨៣

២៥-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៤២៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លំ ជៀន** (LUO JIAN) ជនជាតិចិន សញ្ជាតិចិន ៣៧៨៤

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

០៥-៥-២០១៦ -សេចក្តីសម្រេចលេខ ១៦០/00២/២០១៦ កបធ.ច ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ លើសំណុំរឿង លេខ ២៦១/00២/២០១៦ ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៦ ៣៧៨៥

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

២៨-៤-២០១៦ -អនុក្រឹត្យលេខ ៦៨ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រាមួយចំនួន នៃអនុក្រឹត្យពាក់ព័ន្ធការបង្កើតគណៈកម្មាធិការ ដែលបម្រើឱ្យការងារគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៣៧៩០

២៨-៤-២០១៦ -អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពី ការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ៣៧៩៤

២០-៤-២០១៦ -អនុក្រឹត្យលេខ ៤៣៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨០៣

២០-៤-២០១៦ -អនុក្រឹត្យលេខ ៤៣៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨០៤

២០-៤-២០១៦ -អនុក្រឹត្យលេខ ៤៣៩ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣៨០៦

២០-៤-២០១៦ -អនុក្រឹត្យលេខ ៤៤០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨០៧

២០-៤-២០១៦ -អនុក្រឹត្យលេខ ៤៤១ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣៨០៨

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤២ អនក្រ.តត ស្តីពី ការតែងតាំងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៣៨០៩

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨១០

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៣៨១១

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤៥ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៣៨១៣

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨១៥

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨១៧

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨១៩

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៤៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨២០

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៥០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨២២

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៥១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨២៣

២១-៤-២០១៦ -អនុក្រឹត្យលេខ ៤៥២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣៨២៤

២២-៤-២០១៦ -អនុក្រឹត្យលេខ ៤៥៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨២៥

២២-៤-២០១៦ -អនុក្រឹត្យលេខ ៤៥៤ អនក្រ.តត ស្តីពី ការនិយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ តាមអតីតភាពការងារ ៣៨២៧

២២-៤-២០១៦ -អនុក្រឹត្យលេខ ៤៥៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨២៩

២២-៤-២០១៦ -អនុក្រឹត្យលេខ ៤៥៦ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៣៨៣០

២៥-៤-២០១៦ -អនុក្រឹត្យលេខ ៤៥៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៣២

២៥-៤-២០១៦ -អនុក្រឹត្យលេខ ៤៥៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៣៤

២៥-៤-២០១៦ -អនុក្រឹត្យលេខ ៤៥៩ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៣៨៣៥

## ២-សេចក្តីសម្រេច

២៨-៤-២០១៦ -សេចក្តីសម្រេចលេខ ៣៨ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ៣៨៣៦

២៨-៤-២០១៦ -សេចក្តីសម្រេចលេខ ៣៩ សសរ ស្តីពី ការតែងតាំងសមាសភាព នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ៣៨៣៨

## IV-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៤-០១-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១៦៩ សហវ.ហក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ៣៨៤១

២០-០១-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១៩៦ សហវ.ប្រក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់វិទ្យាស្ថានជាតិអប់រំ ៣៨៤៥

០៧-៣-២០១៦ -ប្រកាសអន្តរក្រសួងលេខ ២០២ សហវ.ប្រក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៣៨៥០

០៧-៣-២០១៦ -ប្រកាសលេខ ២០៥ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តក្រចេះ ៣៨៥៥

០៧-៣-២០១៦ -ប្រកាសលេខ ២០៦ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តក្រចេះ ៣៨៥៧

០៧-៣-២០១៦ -ប្រកាសលេខ ២០៧ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ ៣៨៦០

២៨-៣-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៣០៥ សហវ.ហក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់សម្រាប់បើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ជូនមន្ត្រីរាជការនៅក្រសួងផែនការ ៣៨៦២

០៤-៤-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៣៤៩ សហវ.ហក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ៣៨៦៤

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២២-០១-២០១៦ -ប្រកាសលេខ ០២២ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វេចិចស៊ី ខូលីមីធីត បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៨៦៩

២៥-០១-២០១៦ -ប្រកាសលេខ ០២៣ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញប្លាស្ទិច ប្រូដាក់ បង្កើតរោងចក្រ ផលិតបំពង់ទឹក ធុងទឹក ស៊ីទែនទឹក តុសិស្ស កៅអីសិស្ស គ្រែពេទ្យ និង ផលិតផលពីប្លាស្ទិកផ្សេងៗទៀត ៣៨៧២

២៥-០១-២០១៦ -ប្រកាសលេខ ០២៤ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេ ផ្លាស់ អេស៊ូ (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង ៣៨៧៥

២៥-០១-២០១៦ -ប្រកាសលេខ ០២៥ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន រ៉ាប់ប៊ើរមេនប្រដាក់ អិលធីឌី បង្កើតរោងចក្រ ផលិតសម្ភារៈបំពាក់ក្នុងរថយន្ត (ខ្សែសន្តោង, កម្រាលជើង...) និងសម្ភារៈផ្សេងៗ ៣៨៧៨

២៥-០១-២០១៦ -ប្រកាសលេខ ០២៦ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជុងកាង ស្ទីលស្ត្រាក់ឃ័រ (ខេមបូឌា) បង្កើតរោងចក្រ កែច្នៃដែកធុនធ្ងន់ ៣៨៨១

២៥-០១-២០១៦ -ប្រកាសលេខ ០២៧ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខៃឃី (ខេមបូឌា) វ៉ែរ បង្កើតរោងចក្រ ផលិតតុក្កតា និងបន្ទោងសោគ្រប់ប្រភេទ ៣៨៨៤

២៥-០១-២០១៦ -ប្រកាសលេខ ០២៨ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីកូ (ខេមបូឌា) ខូអិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៨៨៧

២៥-០១-២០១៦ -ប្រកាសលេខ ០២៩ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដុង ឡុង អ៊ិនធើប្រាយ បង្កើតរោងចក្រ ខារអំបោះ ៣៨៩០

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/ ៤១៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម / ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ ឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម :

១- ឯកឧត្តម **ឃ្លោក ជួន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម **មាស សេង** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម **ឡឹក ម៉ុក** មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រណ.១៦០៤.៤២៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៤១៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤១៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជន ០២ រូប ជាអនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល ៖

១- ឯកឧត្តម **ប្រាក់ ចាន់រឿន** ជាអនុរដ្ឋលេខាធិការ

២- ឯកឧត្តម **ប៊ុន ណារិទ្ធ** ជាអនុរដ្ឋលេខាធិការ

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៦០៤.៤២៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៤១៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

នស/រកត/០៤១៦/៤៧០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

LE MINISTRE DU PALAIS ROYAL • ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង

## **ព្រះរាជក្រឹត្យ**

**មាត្រា ១ :** ដាក់មន្ត្រីរាជការ ០៤ រូប របស់ក្រសួង ចំនួន ៤ ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ៖

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

១- ឯកឧត្តម **លីវ ម៉ុនហៃ** ឧត្តមមន្ត្រី ថ្នាក់លេខ ១ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៤

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

២- ឯកឧត្តម **ប្រាក់ ចំរើន** ឧត្តមមន្ត្រី ថ្នាក់លេខ ៥ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

៣- លោក **សេក ឈឿន** ឧត្តមមន្ត្រី ថ្នាក់លេខ ២ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ក្រសួងសុខាភិបាល**

៤- លោកស្រី **ខួយ ម៉ុនថារី** មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៦

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ពរស.១៦០៤.៤២៦*

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៤៣ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៤២១ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤២១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

**ក- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ**

- ឧត្តមសេនីយ៍ត្រី **រស់ រក្សា** អត្តលេខ ៥៤៩៦៨ ។

**ខ- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១- | វរសេនីយ៍ឯក | **ខៃក ចាន់ចណ្ណៈ** | អត្តលេខ ០៤១១៦ |
| ២- | វរសេនីយ៍ឯក | **ពេជ យឹម** | អត្តលេខ ៥៦២៧៨ |
| ៣- | វរសេនីយ៍ឯក | **ទឹម ចន្ថា** | អត្តលេខ ៥៤៦៧៧ |
| ៤- | វរសេនីយ៍ឯក | **ប្រាក់ ម៉ុនថា** | អត្តលេខ ៥៦២៥២ ។ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៧នស.១៦០៤.៤២៧

លេខ: ៤១៧ ស.ណ

**សំណៅចែលមានអត្ថែជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៦

**សយ សុខា**

នស/រកត/០៤១៦/៤៧២

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់ឯកឧត្តម **លីវ គីមហេង** ពីឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៥ មកឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៤១៧ ស.ណ

ចាស.១៦០៤.៤២៤

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤២៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ហែម ចន្ថា** ជានាយកវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ អគ្គនាយក។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ៧. ១៦០៤.៤២៩

លេខ: ៤២៤ ស.ណ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានៈឯកឧត្តម **ពាន់ ជីម** ទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ករម. ១៦០៤.៤៣០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦

លេខ: ៤២៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ន៎ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម់/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូលក្របខ័ណ្ឌ ជាករណីពិសេស លោក **ហឿង សុគន្ធ** ពីឋានន្តរស័ក្តិវរសេនីយ៍ឯក អត្តលេខ ០០៣៩២៤ នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ មកក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦

ការ. ១២០៤.៤៣១

លេខៈ ៤៣៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤២៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

## ដូវ

**ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា :**

១-លោក ISAYAMA OSAMU
២-លោក KIYAMA SATOSHI
៣-លោក ISHII HIDEO

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

១-លោក តូវ សុធារ៉ា
២-លោក ប៉េង សម្បត្តិ
៣-លោក ឡុង វិបុល
៤-លោក ទូច គីម
៥-លោក សៅ វណ្ណៈ
៦-លោក ម៉ៅ សីហា

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

ពរស.១៦០៤.៤៣២

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦

លេខ: ៤២៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤២៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ស៊ី លី** (SHI LI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ នៅខេត្តជាងស៊ូ សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៦០៤.៤៣៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៤៣០ ស.ណ

**សំណៅចម្លងចេញតាមច្បាប់ដើម សម្រាប់ការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ល័រ ជៀន** (LUO JIAN) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៨៣ នៅខេត្តហ៊ូណាន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ. ១៦០៤.៤៣៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៤៣៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៦១/០០២/២០១៦

ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦

**សេចក្តីសម្រេច**

លេខ : ១៦០/០០២/២០១៦ កបធ.ច

ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើលេខ ១៤២ រ.ស ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីសហជីព ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៦ នាសម័យប្រជុំលើកទី៦ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៣ នាថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦ វេលាម៉ោង ១៥ និង ៥៧ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីសហជីព
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីសហជីព ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាលលើចំណុចមួយចំនួននៃច្បាប់ស្តីពីសហជីព ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា គឺពីមាត្រា ១ ដល់ មាត្រា ៤ ដែលចែងពីគោលបំណង គោលដៅ វិសាលភាពនៃច្បាប់ និងនិយមន័យវាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងច្បាប់នេះ។ ជំពូកទី១នេះ ស្របនឹងបទប្បញ្ញត្តិនៃមាត្រា៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា *«ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។»* *«ការរៀបចំនិងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។»*
- យល់ឃើញថា ជំពូកទី២ ស្តីពីសិទ្ធិជាមូលដ្ឋានក្នុងការបង្កើត និងចូលរួមនៅក្នុងសហជីព ឬសមាគមនិយោជក មាន ៦ មាត្រា គឺពីមាត្រា ៥ ដល់ មាត្រា ១០ ដែលចែងពីសិទ្ធិក្នុងការបង្កើត និងការចូលរួមនៅក្នុងសហជីព ឬសមាគមនិយោជក និងរចនាសម្ព័ន្ធសហជីព ឬសមាគមនិយោជក។ ជំពូកទី២នេះ ស្របនឹងបទប្បញ្ញត្តិនៃមាត្រា៣១ វាក្យខ័ណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ដែលចែងថា *«ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និង ករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។»* និងស្របនឹងបទប្បញ្ញត្តិនៃមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៣ ស្តីពីការចុះបញ្ជីសហជីព ឬសមាគមនិយោជក មាន ១១ មាត្រា គឺពីមាត្រា ១១ ដល់ មាត្រា ២១ ដែលចែងពីសិទ្ធិនិងផលប្រយោជន៍នៃការចុះបញ្ជី លក្ខខណ្ឌតម្រូវសម្រាប់លក្ខន្តិកៈ ចំណាត់ការទៅលើការដាក់ពាក្យសុំចុះបញ្ជី ការរក្សាបញ្ជិកា ការលុបបញ្ជិកា លក្ខខណ្ឌ

សម្រាប់អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីពនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន និងរបស់សមាគមនិយោជក។ ជំពូកទី៣នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៤ ស្តីពីហិរញ្ញវត្ថុរបស់សហជីព ឬសមាគមនិយោជក មាន ៦ មាត្រា គឺពីមាត្រា ២២ ដល់ មាត្រា ២៧ ដែលចែងពីប្រភពធនធាននិងហិរញ្ញវត្ថុ វិនិយោគកម្មនៃហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ ការប្រើប្រាស់និងការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ។ ជំពូកទី៤នេះ ស្របនឹងបទប្បញ្ញត្តិ មាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៥ ស្តីពីការរំលាយសហជីព ឬសមាគមនិយោជក មាន ៤ មាត្រា គឺពីមាត្រា ២៨ ដល់ មាត្រា ៣១ ដែលចែងពីការរំលាយសហជីព ឬសមាគមនិយោជក មូលហេតុ អានុភាព និង ទ្រព្យសម្បត្តិរបស់សហជីពឬសមាគមនិយោជកនៅពេលត្រូវបានប្រកាសរំលាយ។ ជំពូកទី៥នេះ ស្របនឹង បទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៦ ស្តីពីតំណាងកម្មករ និយោជិតនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន មាន ១៧ មាត្រា គឺពីមាត្រា ៣២ ដល់ មាត្រា ៤៨ ដែលចែងពីការរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ភារកិច្ចរបស់និយោជក ចំនួនប្រតិភូបុគ្គលិក បេសកកម្មរបស់ប្រតិភូបុគ្គលិក ការការពារប្រតិភូបុគ្គលិក បណ្តឹងតវ៉ាទៅលើលទ្ធផលនៃការបោះឆ្នោត ការចេញប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យ ការងារ។ ជំពូកទី៦នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៧ ស្តីពីសិទ្ធិ និងករណីយកិច្ចរបស់សហជីព មាន ៣ មាត្រា គឺពីមាត្រា ៤៩ ដល់ មាត្រា ៥១ ដែលចែងពីសិទ្ធិនៃសមាជិកភាពនៅក្នុងសហជីព ការតំណាងឱ្យសមាជិកនិងប្រតិភូ សហជីព គោលការណ៍នៃភាពសុចរិតនិងស្មោះត្រង់។ ជំពូកទី៧នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៨ ស្តីពីករណីយកិច្ចរបស់និយោជក និងសមាគមនិយោជក មាន ២ មាត្រា គឺ មាត្រា ៥២ និង មាត្រា ៥៣ ដែលចែងពីបញ្ជីឈ្មោះកម្មករនិយោជិតសម្រាប់សុំភាពជាតំណាងបំផុត គោលការណ៍នៃភាពសុចរិតនិងស្មោះត្រង់។ ជំពូកទី៨នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៩ ស្តីពីការតំណាងដោយសហជីពដែលមានភាពជាតំណាងបំផុត មាន ៨ មាត្រា គឺពីមាត្រា ៥៤ ដល់ មាត្រា ៦១ ដែលចែងពីភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន នៅក្នុង វិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ សិទ្ធិនិងករណីយកិច្ចរបស់សហជីពដែលមានភាពជាតំណាង បំផុត សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិច។ ជំពូកទី៩នេះ ស្របនឹងបទប្បញ្ញត្តិ មាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១០ ស្តីពីការអនុវត្តមិនត្រឹមត្រូវដោយនិយោជក មាន ២ មាត្រា គឺមាត្រា ៦២ និង មាត្រា ៦៣ ដែលចែងពីការមិនរើសអើងដោយសារតែសកម្មភាពរបស់សហជីព សកម្មភាពរបស់និយោជកដែលចាត់ទុកថាអនុវត្តមិនត្រឹមត្រូវ។ ជំពូកទី១០នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១១ ស្តីពីការអនុវត្តមិនត្រឹមត្រូវដោយសហជីព មាន ២ មាត្រា គឺ មាត្រា ៦៤ និង មាត្រា ៦៥ ដែលចែងពីការរើសអើងសមាជិកភាព សកម្មភាពរបស់សហជីពដែលចាត់ទុកថាអនុវត្តមិនត្រឹមត្រូវ។ ជំពូកទី១១នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១២ ស្តីពីការការពារជាពិសេសសម្រាប់កម្មករនិយោជិត និងតំណាងរបស់កម្មករនិយោជិត មាន ៣ មាត្រា គឺពីមាត្រា ៦៦ ដល់ មាត្រា ៦៨ ដែលចែងពីការចូលទៅក្នុងសហគ្រាស ឬគ្រឹះស្ថាន ការការពារចំពោះការបញ្ឈប់ពីការងារ សិទ្ធិចូលក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់អ្នកដឹកនាំសហជីពដែលត្រូវបានបញ្ឈប់ពីការងារ។ ជំពូកទី១២នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៣ ស្តីពីអនុសញ្ញារួម និងការចរចារជាសមូហភាព មាន ៦ មាត្រា គឺពីមាត្រា ៦៩ ដល់ មាត្រា ៧៤ ដែលចែងពីគោលបំណង ថិរវេលា និងការចុះបញ្ជីនៃអនុសញ្ញារួម ភាគីនៃកិច្ចចរចា និងនីតិវិធីដោះស្រាយវិវាទការងារ។ ជំពូកទី១៣នេះ ស្របនឹងបទប្បញ្ញត្តិ មាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៤ ស្តីពីការដោះស្រាយវិវាទរបស់សហជីព ឬសមាគមនិយោជក មាន ១ មាត្រា គឺ មាត្រា ៧៥ ដែលចែងពីការដោះស្រាយវិវាទរបស់សហជីព ឬសមាគមនិយោជក។ ជំពូកទី១៤នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៥ ស្តីពីវិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ មាន ២០ មាត្រា គឺពី មាត្រា ៧៦ ដល់ មាត្រា ៩៥ ដែលចែងពីទណ្ឌកម្មរដ្ឋបាល មានការព្រមានជាលាយលក្ខណ៍អក្សរ និងការពិន័យអន្តរការណ៍ចំពោះអំពើរារាំងដោយខុសច្បាប់នូវសិទ្ធិបង្កើតសហជីព ឬសមាគមនិយោជក អំពើមិនរក្សាទុកកំណត់ត្រាហិរញ្ញវត្ថុ ការធ្វើសកម្មភាពដោយមិនចុះបញ្ជី ឬក្រៅដែនអនុវត្ត ឬដោយមិនសុចរិតនិងស្មោះត្រង់ អំពើបំពានកាតព្វកិច្ចក្នុងការរៀបចំបោះឆ្នោត អំពើបំពានសិទ្ធិរបស់សហជីពដែលមានសមាជិកភាគតិច ការបំពានអនុសញ្ញារួម អំពើរារាំងដោយខុសច្បាប់នូវការធ្វើកូដកម្ម អំពើបង្ខិតបង្ខំឱ្យចូលរួមធ្វើកូដកម្ម ការធ្វើកូដកម្មដោយខុសច្បាប់ និងឡុកអៅដោយខុសច្បាប់ ព្រមទាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។ ជំពូកទី១៥នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥

វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ ស្របនឹងមាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា «*សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្ម ដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់។* » ស្របនឹងមាត្រា ៥២ ឃ្លាទី២ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា «*រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារទឹកដីអធិបតេយ្យ ធានាសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ។* » និងស្របនឹងមាត្រា ១២៨ថ្មី វាក្យខ័ណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា «*អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។*»

- យល់ឃើញថា ជំពូកទី១៦ ស្តីពីអន្តរប្បញ្ញត្តិ មាន ៣ មាត្រា គឺពីមាត្រា ៩៦ ដល់ មាត្រា ៩៨ ដែលចែងពីបញ្ជិកានិងអនុសញ្ញារួមដែលមានស្រាប់ និងតុលាការការងារ។ ជំពូកទី១៦នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៣៦ វាក្យខ័ណ្ឌទី៥ វាក្យខ័ណ្ឌទី៦ និងមាត្រា ១២៨ថ្មី វាក្យខ័ណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៧ ស្តីពីអវសានប្បញ្ញត្តិ មាន ២ មាត្រា គឺមាត្រា ៩៩ និងមាត្រា ១០០ ដែលចែងពីនិរាករណ៍ និងការចូលជាធរមាន។ ជំពូកទី១៧នេះ ស្របនឹងបទប្បញ្ញត្តិមាត្រា ៩៣ថ្មី វាក្យខ័ណ្ឌទី១ ឃ្លាទី២ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា «*ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ។*»
- យល់ឃើញថា ខ្លឹមសារទាំង ១៧ ជំពូក ១០០ មាត្រា នៃច្បាប់ស្តីពីសហជីព ស្របនឹងរដ្ឋធម្មនុញ្ញ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីសហជីព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៣ នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រាមួយចំនួន នៃអនុក្រឹត្យពាក់ព័ន្ធការបង្កើតគណៈកម្មាធិការ ដែលបម្រើឱ្យការងារគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៩៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការផលិតភាពកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រាមួយ.-**

មាត្រាមួយចំនួន នៃអនុក្រឹត្យពាក់ព័ន្ធការបង្កើតគណៈកម្មាធិការ ដែលបម្រើឱ្យការងារគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានធ្វើការកែសម្រួល ដូចខាងក្រោម÷

**ក. អនុក្រឹត្យលេខ ២៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការផលិតភាពកម្ពុជា**

**មាត្រា២ ថ្មី.-**

**គ.៨.ក.** មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងផែនការ | | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ១៥- ទេសាភិបាលធនាគារជាតិនៃកម្ពុជា | | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | សមាជិក |
| ១៧- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |
| ១៨- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| ១៩- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ០១ រូប | សមាជិក |

| | | |
|---|---|---|
| ២០- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ២១- តំណាងប្រតិបត្តិករសេដ្ឋកិច្ច | ០២ រូប | សមាជិក |
| ២២- តំណាងពីមជ្ឈដ្ឋានសិក្សាស្រាវជ្រាវ | ០២ រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ជ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ខ. អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន**

**មាត្រា២ ថ្មី.-**

**គ.អ.ឯ.** មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ១៤- ទេសាភិបាលធនាគារជាតិនៃកម្ពុជា | | សមាជិក |
| ១៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| ១៧- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ០១ រូប | សមាជិក |
| ១៨- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.អ.ឯ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣៖.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានផ្ទេរតំបន់ព្រៃការពារនិងអភិរក្សព្រៃឈើចំនួន១៣កន្លែងដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថាន ដើម្បីគ្រប់គ្រងបន្ត។

**មាត្រា២.-**

ត្រូវបានផ្ទេរតំបន់ព្រៃផ្តល់ផលចំនួន៥កន្លែងដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថាន ដើម្បីគ្រប់គ្រងបន្ត ហើយក្រសួងបរិស្ថាន ត្រូវបន្តនីតិវិធីក្នុងការដាក់បញ្ចូលព្រៃផ្តល់ផលទាំង៥កន្លែងនេះ ជាតំបន់ការពារ និងអភិរក្សព្រៃឈើ។

**មាត្រា៣.-**

ត្រូវបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន៧៣កន្លែងដូចមានក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ ពីក្រសួងបរិស្ថាន ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគ្រប់គ្រងបន្ត។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦

| លរ | ព្រៃការពារ និងតំបន់អភិរក្ស | ផ្ទៃដី(ហិកតា) | ទីតាំង | ក្របខណ្ឌច្បាប់ |
|---|---|---|---|---|
| ១ | តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀលអាងត្រពាំងថ្ម | ១២.៦៥០ | បន្ទាយមានជ័យ | ព្រះរាជក្រឹត្យលេខ ០២០០/១១០ ២២-កុម្ភៈ-២០០០ |
| ២ | តំបន់គ្រប់គ្រងធនធានធម្មជាតិ តំបន់ព្រៃកទឹកសាបនៅក្រុងព្រះសីហនុ | ៦.២០២ | ព្រះសីហនុ | អនុក្រឹត្យលេខ ៧៦ ២០-វិច្ឆិកា-១៩៩៧ |
| ៣ | តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ "ព្រះវិហារ" | ១៩០.០២៧ | ព្រះវិហារ | អនុក្រឹត្យលេខ ៧៦ ៣០-កក្កដា-២០០២ |
| ៤ | តំបន់ព្រៃការពារអភិរក្សដីជម្រាលជួរភ្នំក្រវាញភាគកណ្តាលនិងជីវចម្រុះ | ៤០១.៣១៣ | កោះកុង, ពោធិ៍សាត់ និងកំពង់ស្ពឺ | អនុក្រឹត្យលេខ ៧៧ ៣០-កក្កដា-២០០២ |
| ៥ | តំបន់ព្រៃការពារសម្រាប់អភិរក្សជីវចម្រុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃកោះកុង | ១៤៤.២៧៥ | កោះកុង | អនុក្រឹត្យលេខ ៦៥ ០៦-តុលា-២០០៤ |
| ៦ | តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រៃកល្ពៅ ស្រុកបុរីជលសារ ស្រុកកោះអណ្តែត ខេត្តតាកែវ | ៨.៣០៥ | តាកែវ | អនុក្រឹត្យលេខ ១៤៩ ១៥-តុលា-២០០៧ |
| ៧ | តំបន់ព្រៃការពារសម្រាប់លំហែកម្សាន្ត និងកីឡាប្រមាញ់អូរយ៉ាដាវ ខេត្តរតនគិរី | ១០១.៣៤៨ | រតនគិរី | អនុក្រឹត្យលេខ ៤៧ ២៣-មីនា-២០០៩ |

| | | | | |
|---|---|---|---|---|
| ៨ | តំបន់ព្រៃការពារ និងអភិរក្សជីវចម្រុះសីមា ខេត្តមណ្ឌលគិរី និងក្រចេះ | ២៩២.៦៩០ | មណ្ឌលគិរី និងក្រចេះ | អនុក្រឹត្យលេខ ១៤៣ ០២-កញ្ញា-២០០៩ |
| ៩ | តំបន់គ្រប់គ្រងនិងអភិរក្សដែនបម្រុងសត្វក្រៀលនិងសត្វស្លាបផ្សេងៗ ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត | ២១៧ | កំពត | អនុក្រឹត្យលេខ ០៤ ០៦-មករា-២០១១ |
| ១០ | តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ " មណ្ឌលគិរី " | ៤២៩.៤៣៨ | មណ្ឌលគិរី | អនុក្រឹត្យលេខ ៧៥ ៣០-កក្កដា-២០០២ |
| ១១ | តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង | ៦៦.៩៣២ | ស្ទឹងត្រែង | អនុក្រឹត្យលេខ ៧៧ ២៥-កុម្ភៈ-២០១៤ |
| ១២ | តំបន់ព្រៃការពារសម្រាប់អភិរក្សព្រៃឈើ និងសត្វព្រៃ"ពញាក្រែក" ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ | ១៩៩ | ត្បូងឃ្មុំ | អនុក្រឹត្យលេខ ២៧ ១០-កុម្ភៈ-២០១៦ |
| ១៣ | តំបន់គ្រប់គ្រងនិងអភិរក្សសត្វខ្សឹបនិងជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីរួម ក្នុងភូមិសាស្ត្រកំពង់ធំ និងសៀមរាប | ៣១.១៥៩ | កំពង់ធំ និង សៀមរាប | ប្រកាសលេខ ៦៤ ០៨-កុម្ភៈ-២០១០ |

**ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦**

| ល.រ | ទីតាំងព្រៃ | ខេត្ត | ផ្ទៃដី(ហត) |
|---|---|---|---|
| ១ | ព្រៃឡង់ | ក្រចេះ ស្ទឹងត្រែង និងកំពង់ធំ | ៣០៥.៣៦៦ |
| ២ | ព្រៃច្រករបៀងក្រវាញខាងត្បូង | កំពង់ស្ពឺ ពោធិ៍សាត់ និងកោះកុង | ៤៤៣.១៣៤ |
| ៣ | ព្រៃព្រះរការ | ព្រះវិហារ | ៨០.៨២៣ |
| ៤ | ព្រៃសៀមប៉ាងលិច | ស្ទឹងត្រែង | ៦៥.០៧០ |
| ៥ | ព្រៃវីនសៃ-សៀមប៉ាង | ស្ទឹងត្រែង និង រតនគិរី | ៥៦.៩៣២ |

## ឧបសម្ព័ន្ធ ៣ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦

